Khmer

# សុវត្ថិភាពតាមអនឡាញសម្រាប់មាតាបិតា និងអ្នកថែទាំ

**អ៊ីនធើណិតគឺជាផ្នែកដ៏សំខាន់មួយនៃពិភពរបស់កូនអ្នក - សម្រាប់ការអប់រំ ការទាក់ទងខាងសង្គម និងការកម្សាន្ត។**

**ក្នុងឋានៈជាឪពុកម្តាយ និងអ្នកថែទាំ អ្នកអាចជួយកូនរបស់អ្នករុករកពិភពឌីជីថលរបស់ពួកគេ និងអប់រំពួកគេអំពីរបៀបជៀសវាងបទពិសោធន៍ដែលបង្កគ្រោះថ្នាក់នៅតាមអនឡាញ ហើយដោះស្រាយជាមួយពួកគេ ប្រសិនបើបទពិសោធន៍អវិជ្ជមានកើតឡើង។**

និយាយទៅកាន់កូនរបស់អ្នកឱ្យបានឆាប់ ហើយជាញឹកញាប់អំពីអ្វីដែលពួកគេកំពុងធ្វើនៅតាមអនឡាញ។ សម្រាប់គន្លឹះដ៏មានប្រយោជន៍ និងដំបូន្មានអំពីរបៀបជួយកូនរបស់អ្នកឱ្យមានសុវត្ថិភាពតាមអនឡាញ សូមចូលទៅកាន់វ៉ិបសៃថ៍ eSafety នៅត្រង់ **esafety.gov.au/parents**។

## ការសម្លុតធ្វើបាបតាមអនឡាញ

ការសម្លុតធ្វើបាបតាមអនឡាញ អាចមានក្នុងទម្រង់ជាច្រើនដូចជាការផ្ញើសារប្រមាថ រូបភាព ឬវីដេអូដែលធ្វើឱ្យឈឺចាប់ ការនិយាយដើមអាក្រក់ ឬការមិនរាប់បញ្ចូល ឬការធ្វើឱ្យអាម៉ាស់មុខអ្នកឯទៀតតាមអនឡាញ។ កូនរបស់អ្នកប្រហែលជាព្រួយបារម្ភថា ប្រសិនបើពួកគេនិយាយមកកាន់អ្នក នោះការសម្លុតធ្វើបាបនឹងរឹតកាន់តែអាក្រក់ ឬអ្នកអាចដកហូតការប្រើប្រាស់អ៊ីនធើណិតរបស់ពួកគេ ឬទូរស័ព្ទដៃរបស់ពួកគេ។

សញ្ញាមួយចំនួនដែលអាចចង្អុលបង្ហាញថា កូនរបស់អ្នកកំពុងត្រូវបានគេការសម្លុតធ្វើបាប រួមមាន៖

- មានការអាក់អន់ចិត្តបន្ទាប់ពីការប្រើប្រាស់អ៊ីនធើណិត ឬទូរស័ព្ទដៃរបស់ពួកគេ ឬក្លាយទៅជាលាក់ការសម្ងាត់អំពីសកម្មភាពតាមអនឡាញ និងការប្រើទូរស័ព្ទដៃរបស់ពួកគេ
- ដកខ្លួនចេញពីមនុស្សឯទៀត អន្ទះសារ ឬខឹង ហាក់ដូចជាមនុស្សឯកកោ ឬកើតទុក្ខព្រួយ
- ចង់គេចវៀសទៅសាលារៀន ឬមានការអន់ខ្សោយលើការសិក្សា

ដើម្បីស្វែងយល់បន្ថែមអំពីរបៀបនិយាយទៅកាន់កូនរបស់អ្នក អំពីឥរិយាបទតាមអនឡាញដោយគោរពចាប់ពីវ័យនៅក្មេង ហើយត្រូវប្រាកដថាពួកគេដឹងថា ពួកគេអាចមករកអ្នកអំពីការព្រួយបារម្ភណាមួយ សូមចូលទៅកាន់វ៉ិបសៃថ៍ eSafety នៅត្រង់ **esafety.gov.au/parents/big-issues/cyberbullying**

## ទំនាក់ទំនងដែលមិនចង់បាន

តើអ្នកដឹងថា កូនរបស់អ្នកកំពុងនិយាយជាមួយនរណាតាមអនឡាញឬទេ? យើងទាំងអស់គ្នាចង់ការពារមនុស្សវ័យក្មេងរបស់យើងពីការទាក់ទងជាមួយជនចម្លែក ជាពិសេសនរណាម្នាក់ដែលអាចធ្វើឱ្យឈឺចាប់ដល់កូនរបស់អ្នក។

ធ្វើបច្ចុប្បន្នភាពនូវវ៉ិបសៃថ៍ និងកម្មវិធីដែលកូនរបស់អ្នកកំពុងប្រើប្រាស់ ហើយលើកទឹកចិត្តឱ្យពួកគេនិយាយមកកាន់អ្នក ប្រសិនបើនរណាម្នាក់នៅតាមអនឡាញ កំពុងស្នើសុំឱ្យពួកគេធ្វើអ្វីដែលមិនត្រឹមត្រូវ។ ជួយកូនរបស់អ្នកឱ្យចេះប្រុងប្រយ័ត្នចំពោះសញ្ញានៃការទាក់ទងតាមអនឡាញដែលមិនប្រក្រតី ដូចជាត្រូវបានសួរ៖

- សំណួរជាច្រើនអំពីព័ត៌មានផ្ទាល់ខ្លួន ភ្លាមៗបន្ទាប់ពីទំនាក់ទំនងដំបូង
- អែបអបរកប្រយោជន៍ដោយឱ្យរង្វាន់អំណោយ និងការសន្យាដើម្បីជាគុណប្រយោជន៍ត្រឡប់មកវិញ
- ដើម្បីធ្វើទំនាក់ទំនងតាមវិធីផ្សេងទៀត ដូចជាការជជែកលេងតាមអនឡាញ និងការផ្ញើសារគ្នាទៅវិញទៅមក
- នរណាប្រើប្រាស់ខុមព្យូធើររបស់ពួកគេរួមគ្នា ហើយថាតើខុមព្យូធើរនោះនៅបន្ទប់មួយណា
- សម្រាប់ព័ត៌មានស្និទ្ធស្នាល
- ដើម្បីរក្សាទំនាក់ទំនងរបស់ពួកគេជាសម្ងាត់
- ដើម្បីជួបពួកគេដោយផ្ទាល់

ដើម្បីស្វែងយល់ពីរបៀបទប់ស្កាត់ទំនាក់ទំនងដែលមិនចង់បាន និងសម្រាប់មគ្គុទេសក៍ដ៏ទូលំទូលាយបន្ថែមទៀត ដើម្បីគ្រប់គ្រងទំនាក់ទំនងដែលមិនចង់បាន សូមចូលទៅកាន់វ៉ិបសៃថ៍ eSafety នៅត្រង់ **esafety.gov.au/parents/big-issues/unwanted-contact**

## ការផ្ញើសាររូបភាពអាក្រាត និងការផ្ញើរូបភាពអាក្រាត

វាជាការសំខាន់ក្នុងការនិយាយទៅកាន់កូនរបស់អ្នក នៅពេលដែលពួកគេកាន់តែមានវ័យធំ អំពីផលវិបាកដែលអាចកើតមានពីការផ្ញើ ឬការចែករំលែករូបភាព ឬវីដេអូដែលស្និទ្ធស្នាល ឬច្បាស់លាស់ដែលត្រូវបានគេស្គាល់ផងដែរថា Nudes ឬ Noods (ស្រាត)។

ខណៈពេលដែលការផ្ញើសាររូបភាពអាក្រាត អាចមិនជារឿងធម្មតាដូចដែលអ្នក និងកូនរបស់អ្នកគិតឃើញនោះ វាជាការសំខាន់ដែលត្រូវដឹងអំពីហានិភ័យនៃការចែករំលែករូបភាពស្និទ្ធស្នាល។ សូម្បីតែមិត្តភក្តិដែលទុកចិត្ត ក៏អាចមានបញ្ហាដែរ។

ការចែករំលែកដែលមិនចង់បាននូវរូបភាពសំខាន់ៗផ្ទាល់ខ្លួនរបស់អ្នក អាចនាំឱ្យមានការអាម៉ាស់ ការសម្លុតធ្វើបាប និងធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់មនុស្សវ័យក្មេង។ ពេលណារូបភាពត្រូវបានចែករំលែកហើយនោះ កុមារបាត់បង់ការគ្រប់គ្រងលើរូបភាពនោះហើយ ហើយវាអាចត្រូវបានគេផ្សព្វផ្សាយគ្រប់ទីកន្លែងនៅលើអ៊ីនធើណិត។

កំណត់សម្គាល់: ការបង្កើត ឬការចែករំលែកនូវរូបអាសអាភាសរបស់កុមារ និងមនុស្សវ័យក្មេងដែលមានអាយុក្រោម១៨ឆ្នាំ គឺខុសច្បាប់ ហើយអាចនាំឱ្យជាប់បទល្មើសខាងបទឧក្រិដ្ឋ និងការពិន័យ។

ដើម្បីស្វែងយល់បន្ថែមអំពីរបៀបនិយាយទៅកាន់កូនរបស់អ្នក អំពីការផ្ញើសាររូបភាពអាក្រាត និងការផ្ញើរូបភាពអាក្រាត និងគន្លឹះដ៏មានប្រយោជន៍អំពីអ្វីដែលត្រូវធ្វើ ប្រសិនបើកូនរបស់អ្នកផ្ញើ ឬទទួលរូបភាពអាក្រាត សូមចូលទៅកាន់វ៉ិបសៃថ៍ eSafety នៅត្រង់ **esafety.gov.au/parents/big-issues/sending-nudes-sexting**



## ឧបករណ៍ គន្លឹះដ៏មានប្រយោជន៍ និងដំបូន្មាន

អ្នកអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយកូនរបស់អ្នកឱ្យមានសុវត្ថិភាពតាមអនឡាញ។ ការបើកចំហ ការទាក់ទិន និងការគាំទ្រគឺមានសារៈសំខាន់ក្នុងការជួយពួកគេឱ្យបង្កើតទម្លាប់ល្អតាមអនឡាញ និងបញ្ហាខាងឌីជីថល។

ស្វែងយល់ពីឧបករណ៍ឌីជីថលដែលកូនរបស់អ្នកកំពុងប្រើប្រាស់ ហើយជាមួយគ្នានោះ ព្រមព្រៀងគ្នាអំពីវិន័យសម្រាប់ការចូលប្រើតាមអនឡាញ។ វិន័យទាំងនេះអាចត្រូវបានពិនិត្យឡើងវិញនៅពេលកូនរបស់អ្នកមានវ័យធំ។

សំខាន់បំផុត ចូររក្សាឱ្យបណ្ដាញទំនាក់ទំនងនៅបើកចំហ ស្ដាប់ពួកគេ ហើយកុំវិនិច្ឆ័យឱ្យសោះ។

**សូមចូលទៅកាន់វ៉ិបសៃថ៍ eSafety.gov.au/languages សម្រាប់ព័ត៌មានបន្ថែម។**

**ជួយកូនរបស់អ្នកឱ្យមានសុវត្ថិភាពតាមអនឡាញ។**

**ចាប់ផ្ដើមជជែក។**